ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣...ស.ជ.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការថែរក្សា រៀបចំទុកដាក់អដ្ឋិធាតុប្រជាជនរងគ្រោះ ដោយអំពើប្រល័យពូជសាសន៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) និងការរៀបចំតំបន់អន្លង់វែងឱ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ

---

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ ១៩៧៩ភ្លាម ទឹកដីកម្ពុជាទាំងមូល មានរណ្តៅសាកសពរូមជាច្រើនកន្លែង ដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបន្សល់ទុកជាវត្ថុតាងនៃឧក្រិដ្ឋកម្មមកលើប្រជាជនស្លូតត្រង់ ។ ភ្លាមនោះ អាជ្ញាធរ និងប្រជាពលរដ្ឋ បានខិតខំយកអដ្ឋិធាតុរបស់ជនរងគ្រោះ មកថែរក្សាតំកល់ទុកបានគត់មត់ល្អ កន្លែងខ្លះបានធ្វើស្តូប និងបានធ្វើកន្លែងតំកល់ទុកដាក់ជាបូជនីយដ្ឋានបានសមរម្យ ។ ប៉ុន្តែ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅកន្លែងដែលបានតំកល់ទុកអដ្ឋិធាតុពីមុន ពុំទាន់បានយកចិត្តទុកដាក់ថែរក្សាឱ្យបានល្អជាប្រចាំនៅឡើយ ។

ដើម្បីថែរក្សាទុកអដ្ឋិធាតុជាភស្តុតាងនៃឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រ សំរាប់ជាមូលដ្ឋានរំលឹកអប់រំដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ពិសេសដល់វ័យជំនាន់ក្រោយ ឱ្យចងចាំជានិច្ចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់ខ្លោចផ្សា និងជូរចត់បំផុត ដែលរបបកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តមកលើប្រជាជន និងទឹកដីមាតុភូមិកម្ពុជា កាលពីឆ្នាំ ១៩៧៥-១៩៧៨ អស់រយៈកាល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃនេះ ជាពិសេស ការរៀបចំថែរក្សាតំបន់អន្លង់វែងសំរាប់ធ្វើជាសារមន្ទីរប្រវត្តិសាស្ត្រជូនដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនា ពេលអនាគត រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ :

១- អាជ្ញាធរដែនដី ខេត្ត-ក្រុង ទាំងអស់ សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធនៅជុំវិញ ខេត្ត-ក្រុង ត្រូវពិនិត្យជួសជុល និងថែរក្សាឡើងវិញ ឱ្យបានល្អនូវកន្លែងតំកល់អដ្ឋិធាតុទាំងឡាយដែលបានធ្វើកន្លងមក ហើយត្រូវពិនិត្យស្រាវជ្រាវនូវរណ្តៅដែលនៅសេសសល់ ដើម្បីរៀបចំកន្លែងទាំងអស់នេះ ឱ្យទៅជាបូជនីយដ្ឋានដែលមានរបងហ៊ុំព័ទ្ធមានដាំដើមឈើ និងដាក់ផ្លាកសញ្ញាពតិមានប្រវត្តិសាស្ត្រឱ្យបានល្អ ដើម្បីបង្ហាញជូនដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ត្រូវធ្វើការណែនាំបន្ថែមអំពីផ្នែកបច្ចេកទេស ហើយត្រូវចាត់តាំងមន្ត្រីជំនាញក្រោមឱវាទ ឱ្យចុះសហការជាមួយអាជ្ញាធរដែនដី ក្នុងកិច្ចការនេះ ។

២- ដោយឡែកនៅតំបន់អន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាតំបន់ប្រវត្តិសាស្ត្រនៃជីវិតនយោបាយចុងក្រោយរបស់មេដឹកនាំ និងអង្គការចាត់តាំងខាងយោធារបស់ខ្មែរក្រហម ប៉ុល ពត ក្រសួងទេសចរណ៍ត្រូវខិតខំបន្តអនុវត្តដូចដែលរាជរដ្ឋាភិបាល បានណែនាំកន្លងមក ដោយត្រូវសហការជាមួយអាជ្ញាធរដែនដី ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យោធភូមិភាគទី ៤ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC) និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការបោសសំអាតមីន រៀបចំប្លង់មេឱ្យបានត្រឹមត្រូវស្រាវជ្រាវឯកសាររៀបចំជាសារៈមន្ទីរប្រវត្តិសាស្ត្រ ដោយខិតខំស្វែងរកគ្រប់ប្រភពជាំការជន្នៈ ដើម្បីធ្វើការរៀបចំថែរក្សានូវភស្តុតាងប្រវត្តិសាស្ត្រទាំងអស់ និងសំរាប់កសាង រៀបចំតំបន់នោះ ឱ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយរបស់ប្រទេសជាតិ ។

ហាមឃាត់ដាច់ខាតនូវការរំលោភយកដីធ្លី និងការបែងចែកដីធ្លីបែបអនាធិបតេយ្យ ឬការសាងសង់សំណង់ណាមួយ នៅតំបន់អន្លង់វែង ដែលធ្វើឱ្យមានការប៉ះពាល់ដល់តំបន់ប្រវត្តិសាស្ត្រនេះ ដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល លើកលែងតែការកសាងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំនោះ ដែលត្រូវបានអនុញ្ញាតស្របតាមការកំណត់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

៣- ត្រូវយកចិត្តទុកដាក់ខិតខំអនុវត្តកិច្ចការទាំងអស់ខាងលើ ឱ្យបានមុនថ្ងៃ ៧មករា ឆ្នាំ ២០០២នេះ ដែលជាខួបលើកទី ២៣ នៃថ្ងៃផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ